ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខៈ ...១០៥/១៧...ស.ស.រ

# សេចក្ដីសម្រេច
## ស្ដីពី
## ការតែងតាំងសមាសភាព
## គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តមណ្ឌលគិរី

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៨០៨ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៤ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- បានឃើញអនុក្រឹត្យលេខ ២៧៣ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- បានឃើញសេចក្ដីសម្រេចរាជរដ្ឋាភិបាល លេខ១៤៥សសរ ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ២០១៤ ស្ដីពីការតែងតាំង សមាសភាពគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- បានឃើញសេចក្ដីសម្រេចលេខ ០០១/១៤សសរ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ
- យោងតាមសំណើលេខ ០៦០/១៧ លស ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ របស់រដ្ឋបាលខេត្តមណ្ឌលគិរី

## សម្រេច

**ប្រការ ១** : ត្រូវបានតែងតាំង ឯកឧត្តម **ស្វាយ សំអ៊ាង** អភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី ជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តមណ្ឌលគិរី ជំនួសឯកឧត្តម **អេង ម៉ុនអ៊ាង** ដែលត្រូវបានត្រាស់បង្គាប់ផ្ទេរភារកិច្ចឲ្យមកបំពេញការងារនៅទីស្ដីការក្រសួងមហាផ្ទៃ តាមព្រះរាជក្រឹត្យលេខ នស/រកត/០២១៦/១៣៧ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦។

**ប្រការ២** : ឯកឧត្តម **ស្វាយ សំអ៊ាង** អនុប្រធាន និងសមាជិក សមាជិកា នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តមណ្ឌលគិរី មានភារកិច្ចអនុវត្តសេចក្ដីសម្រេចលេខ ០០១/១៤ សសរ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៤ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ស្ដីពីការ

រៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ ឲ្យមានប្រសិទ្ធភាព។

**ប្រការ៣** : សេចក្តីសម្រេចនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ មិថុនា ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ជ.ប.ជ**

**សម្តេចក្រឡាហោម ស ខេង**

**ចម្លងជូន**

-សមាជិក គ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

-គណៈកម្មាធិការ គ.រ.ប.ជ និង គ.ខ.ប.ជ

"ដើម្បីអនុវត្ត"

-ឯកសារ កាលប្បវត្តិ